| ៩៥ | លោក | អ៊ឹម | ណារឿម | មន្ត្រីរដ្ឋបាល | អនុ.អង្គជោតិ | អង្គរជ័យ |
| ៩៦ | លោក | យន់ | រ៉ាន់ដេង | មន្ត្រីរដ្ឋបាល | អនុ.អង្គភ្នំតូច | អង្គរជ័យ |
| ៩៧ | លោក | ខៃង | ញ៉ូយ | មន្ត្រីរដ្ឋបាល | សាលាបឋម សំឡាញ | អង្គរជ័យ |
| ៩៨ | លោក | អ៊ុក | រេម | មន្ត្រីរដ្ឋបាល | សាលាបឋម ម្រោម | អង្គរជ័យ |
| ៩៩ | លោក | រ៉ាត | ប៊ុនធឿន | មន្ត្រីរដ្ឋបាល | សាលាបឋម ដំបូកខ្ពស់ | អង្គរជ័យ |
| ១០០ | លោក | អ៊ុំ | កប | មន្ត្រីរដ្ឋបាល | វិ. ហ ស អង្គស្នួល | អង្គរជ័យ |
| ១០១ | លោក | តែង | ម៉ាង | មន្ត្រីរដ្ឋបាល | អនុ. វត្តអង្គជ័យ | អង្គរជ័យ |

| | | | | | | |
|---|---|---|---|---|---|---|
| ១០២ | លោក | នៅ | អឿន | មន្ត្រីរដ្ឋបាល | អនុ.អង្គស្វាយពុំសែន | អង្គរជ័យ |
| ១០៣ | លោក | អេង | បូ | មន្ត្រីរដ្ឋបាល | វិ.ជាស៊ីមអង្គរជ័យ | អង្គរជ័យ |
| ១០៤ | លោកស្រី | តូច | ស៊ីម៉ើ | មន្ត្រីរដ្ឋបាល | សាលាបឋម អង្គមន្ត្រី | អង្គរជ័យ |
| ១០៥ | លោក | នួន | វ៉ាន់ | មន្ត្រីរដ្ឋបាល | អនុ. ហ ស អង្គរជ័យ | អង្គរជ័យ |
| ១០៦ | លោក | អោម | ម៉ុន | មន្ត្រីរដ្ឋបាល | បឋមអម្ពវ័ន្តយោធារ៉ាម | ជុំគិរី |
| ១០៧ | លោក | សុខ | វឿន | មន្ត្រីរដ្ឋបាល | សាលាបឋម ជម្ពូវ័ន្ត | ជុំគិរី |
| ១០៨ | លោក | ស៊ីវ | អ៊ីង | មន្ត្រីរដ្ឋបាល | សាលាបឋម ជ្រេស | ជុំគិរី |
| ១០៩ | លោក | សំ | ចាន់ធីយ៉ា | មន្ត្រីរដ្ឋបាល | សាលាបឋម អង្គចក | ជុំគិរី |
| ១១០ | លោក | ម៉ី | មុនី | មន្ត្រីរដ្ឋបាល | សាលាបឋម វត្តអូរ | កំពង់ត្រាច |
| ១១១ | លោក | ណែន | វុទ្ធី | មន្ត្រីរដ្ឋបាល | សាលាបឋម ថ្មបើក | កំពង់ត្រាច |
| ១១២ | លោក | ម៉ៅ | ណូន | មន្ត្រីរដ្ឋបាល | សាលាបឋម កំពូលមាស | កំពង់ត្រាច |
| ១១៣ | លោក | កែម | វណ្ណៈ | មន្ត្រីរដ្ឋបាល | សាលាបឋម អូរពពូល | កំពង់ត្រាច |
| ១១៤ | លោក | ហ៊ឹង | វ៉ាន់ | មន្ត្រីរដ្ឋបាល | សាលាបឋម កោះទ្រមូង | កំពង់ត្រាច |
| ១១៥ | លោក | ឱក | សារឿន | មន្ត្រីរដ្ឋបាល | សាលាបឋម ឫស្សីស្រុក | កំពង់ត្រាច |
| ១១៦ | លោកស្រី | ឃិន | សុភា | មន្ត្រីរដ្ឋបាល | សាលាបឋម ហ សសិស្សល្អ | កំពង់ត្រាច |
| ១១៧ | លោក | អ៊ឹម | កុមាចយ | មន្ត្រីរដ្ឋបាល | សាលាបឋម អូរស្លែង | កំពង់ត្រាច |
| ១១៨ | លោក | ជា | នាក់ | មន្ត្រីរដ្ឋបាល | សាលាបឋម ភូមិថ្កូវ | កំពង់ត្រាច |
| ១១៩ | លោក | ម៉ៅ | ហ៊ី | មន្ត្រីរដ្ឋបាល | អនុ.កំពូលមាស | កំពង់ត្រាច |
| ១២០ | លោក | យ៉ុង | វិចិត្រ | មន្ត្រីរដ្ឋបាល | មន្ទីរ អ យ ក ខេត្ត | ក្រុង កំពត |
| ១២១ | លោក | វ៉ាន់ | វិសាល | មន្ត្រីរដ្ឋបាល | មន្ទីរ អ យ ក ខេត្ត | ក្រុង កំពត |
| ១២២ | លោក | នាក់ | បញ្ញា | មន្ត្រីរដ្ឋបាល | មន្ទីរ អ យ ក ខេត្ត | ក្រុង កំពត |
| ១២៣ | លោក | ថោង | ចិន្តាប់ | មន្ត្រីរដ្ឋបាល | មន្ទីរ អ យ ក ខេត្ត | ក្រុង កំពត |
| ១២៤ | លោក | ផន | ស្រ៊ីន | មន្ត្រីរដ្ឋបាល | មន្ទីរ អ យ ក ខេត្ត | ក្រុង កំពត |
| ១២៥ | លោក | ថន | រដ្ឋា | មន្ត្រីរដ្ឋបាល | មន្ទីរ អ យ ក ខេត្ត | ក្រុង កំពត |
| ១២៦ | លោក | ឃិន | សិលា | មន្ត្រីរដ្ឋបាល | មន្ទីរ អ យ ក ខេត្ត | ក្រុង កំពត |
| ១២៧ | លោក | វ៉ង្ហុល | យឿន | មន្ត្រីរដ្ឋបាល | មន្ទីរ អ យ ក ខេត្ត | ក្រុង កំពត |
| ១២៨ | លោកស្រី | លាង | សុភាព | មន្ត្រីរដ្ឋបាល | មន្ទីរ អ យ ក ខេត្ត | ក្រុង កំពត |

| | | | | | | |
|---|---|---|---|---|---|---|
| ១២៩ | លោក | ទី | សុខុម | គ្រូបង្រៀន | អនុវិទ្យាល័យត្រពាំងរពៅ | ទឹកឈូ |
| ១៣០ | លោក | ឡេង | ដួង | គ្រូបង្រៀន | សាលាបឋមផ្សារអំពៅ | ទឹកឈូ |
| ១៣១ | លោកស្រី | ឈាវ | សុខុម | គ្រូបង្រៀន | សាលាបឋមរស្មីខេមរៈ | ទឹកឈូ |
| ១៣២ | លោកស្រី | ហ៊ាវ | បួយ | គ្រូបង្រៀន | សាលាបឋមកំពង់នង់ | ទឹកឈូ |
| ១៣៣ | លោក | នាក់ | សុទ្ធា | គ្រូបង្រៀន | សាលាបឋមត្រពាំងធំ | ទឹកឈូ |
| ១៣៤ | លោក | គុយ | តារា | គ្រូបង្រៀន | សាលាបឋមមាត់ពាម | ទឹកឈូ |
| ១៣៥ | លោកស្រី | អ៊ឹង | ចាន់និមល | គ្រូបង្រៀន | វិ.ព្រះនរោត្តមរណឫទ្ធិ | ទឹកឈូ |
| ១៣៦ | លោក | យូ | សាមឿន | គ្រូបង្រៀន | អនុវិទ្យាល័យកូនសត្វ | ទឹកឈូ |
| ១៣៧ | លោក | លឹម | ឡៀត | គ្រូបង្រៀន | សាលាបឋមកូនសត្វ | ទឹកឈូ |
| ១៣៨ | លោក | ស៊ីន | សម្បត្តិ | គ្រូបង្រៀន | សាលាបឋមទួលពន្លៃ | ទឹកឈូ |
| ១៣៩ | លោក | កែវ | សារ៉ន | គ្រូបង្រៀន | សាលាបឋមបុះត្របែក | ទឹកឈូ |
| ១៤០ | លោក | អេង | រ៉ាត | គ្រូបង្រៀន | សាលាបឋមរលួស | ទឹកឈូ |
| ១៤១ | លោក | ម៉ែន | សិត | គ្រូបង្រៀន | សាលាបឋមព្រៃថ្កូង | ទឹកឈូ |
| ១៤២ | លោកស្រី | សុខ | ម៉ាលី | គ្រូបង្រៀន | អនុវិទ្យាល័យរោងចក្រ | ទឹកឈូ |
| ១៤៣ | លោកស្រី | យន | ចន្ធូ | គ្រូបង្រៀន | វិ.ហសត្រសេកកោង | ទឹកឈូ |
| ១៤៤ | លោកស្រី | ជៀប | សុផាន់ណា | គ្រូបង្រៀន | សាលាបឋមភ្នំស | ទឹកឈូ |
| ១៤៥ | លោកស្រី | ម៉ាន់ | ប៊ុណ្ណា | គ្រូបង្រៀន | សាលាបឋមកំពង់ត្រែង | ទឹកឈូ |
| ១៤៦ | លោកស្រី | ជួប | តារាសុជាតិ | គ្រូបង្រៀន | សាលាបឋមវត្តអង្គ | ទឹកឈូ |
| ១៤៧ | ឥលោក | ញាណ | សាឡែសង | គ្រូបង្រៀន | វិទ្យាល័យហ ស ឈូក | ឈូក |
| ១៤៨ | លោកស្រី | ជួន | បូផាន់ | គ្រូបង្រៀន | វិ.មាសសុភាចានៀវ | ឈូក |
| ១៤៩ | លោក | ទូច | ថៃឡាត | គ្រូបង្រៀន | អនុ.ប៊ុនរ៉ានីហសនារាយណ៍ | ឈូក |
| ១៥០ | លោក | គី | សុន | គ្រូបង្រៀន | អនុ.ឈើទាលជ្រុំ | ឈូក |
| ១៥១ | លោកស្រី | ឈឺន | ផល្លា | គ្រូបង្រៀន | សាលាបឋមអង្គម្រះព្រៅ | ឈូក |
| ១៥២ | លោក | សុខ | វុធ | គ្រូបង្រៀន | សាលាបឋម ប្រមូល | ឈូក |
| ១៥៣ | លោក | នោម | ចាត | គ្រូបង្រៀន | សាលាបឋមក្រាំងរលួស | ឈូក |
| ១៥៤ | លោក | ជា | ម៉ាប់ | គ្រូបង្រៀន | សាលាបឋមអង្គឈូក | ឈូក |
| ១៥៥ | លោក | នាង | សុជាតិ | គ្រូបង្រៀន | សាលាបឋមនារាយណ៍ | ឈូក |

| | | | | | | |
|---|---|---|---|---|---|---|
| ១៥៦ | លោក | ម៉ម | ម៉ុន | គ្រូបង្រៀន | សាលាបឋមដីក្រហម | ឈូក |
| ១៥៧ | លោក | ណឹម | សុវណ្ណ | គ្រូបង្រៀន | សាលាបឋមហសកោះស្លា | ឈូក |
| ១៥៨ | លោក | អ៊ូ | សារិទ្ធិ | គ្រូបង្រៀន | សាលាបឋម បានៀវ | ឈូក |
| ១៥៩ | លោក | ឡូន | វណ្ណសាត | គ្រូបង្រៀន | សាលាបឋម វត្តស្ទឹង | ឈូក |
| ១៦០ | លោក | សួន | សុខុម | គ្រូបង្រៀន | សាលាបឋមត្រពាំងបី | ឈូក |
| ១៦១ | លោក | ផាង | ថៃ | គ្រូបង្រៀន | សាលាបឋម បឹងនិមល | ឈូក |
| ១៦២ | លោក | រស់ | បូរ | គ្រូបង្រៀន | វិ.ប៊ុនរ៉ានី ហ ស ដងទង់ | ដងទង់ |
| ១៦៣ | លោកស្រី | អ៊ី | ឡៃម | គ្រូបង្រៀន | អនុវិ.ត្រពាំងគ្រាញ់ | ដងទង់ |
| ១៦៤ | លោក | អ៊ិន | សុខជា | គ្រូបង្រៀន | អនុវិទ្យាល័យរោងវែង | ដងទង់ |
| ១៦៥ | លោក | សំ | ឌុន | គ្រូបង្រៀន | សាលាបឋម ឈ្មឹតក្រោម | ដងទង់ |
| ១៦៦ | លោក | សូ | វ៉ា | គ្រូបង្រៀន | សាលាបឋមដំណាក់អំពិល | ដងទង់ |
| ១៦៧ | លោក | ឈិត | សំអាង | គ្រូបង្រៀន | សាលាបឋម ដងទង់ថ្មី | ដងទង់ |
| ១៦៨ | លោកស្រី | អ៊ិន | ស៊ីណា | គ្រូបង្រៀន | សាលាបឋម ព្រៃសំណាង | ដងទង់ |
| ១៦៩ | លោកស្រី | ឆឹង | ហាយ | គ្រូបង្រៀន | សាលាបឋម ដំណាក់ | ដងទង់ |
| ១៧០ | លោក | ម៉ៅ | សេរីវុឌ្ឍ | គ្រូបង្រៀន | អនុ. ពញាអង្គរ | បន្ទាយមាស |
| ១៧១ | លោក | តាំ | សុខា | គ្រូបង្រៀន | សាលាបឋមព្រៃក្រឡា | បន្ទាយមាស |
| ១៧២ | លោក | គ្រុយ | យ៉េក | គ្រូបង្រៀន | វិទ្យាល័យហសបរិវាស | បន្ទាយមាស |
| ១៧៣ | លោក | ម៉ប់ | ធីម៉ា | គ្រូបង្រៀន | វិទ្យាល័យហសបរិវាស | បន្ទាយមាស |
| ១៧៤ | លោកស្រី | កៅ | ស្រី | គ្រូបង្រៀន | សាលាបឋមជ្រុងស្រឡៅ | បន្ទាយមាស |
| ១៧៥ | លោក | ហ៊ឹម | សុខា | គ្រូបង្រៀន | សាលាបឋមត្រពាំងពោន | បន្ទាយមាស |
| ១៧៦ | លោកស្រី | កែន | ស្រីមុំ | គ្រូបង្រៀន | សាលាបឋម ក្តីចាស់ | បន្ទាយមាស |
| ១៧៧ | លោកស្រី | ធាំ | សាមឿន | គ្រូបង្រៀន | សាលាបឋម ព្រៃរោង | បន្ទាយមាស |
| ១៧៨ | លោក | កែ | ផុន | គ្រូបង្រៀន | សាលាបឋម ព្រៃស្វាយ | បន្ទាយមាស |
| ១៧៩ | លោក | កៅ | ឡោ | គ្រូបង្រៀន | សាលាបឋម អង្គធាយ | បន្ទាយមាស |
| ១៨០ | លោកស្រី | សេង | សុខា | គ្រូបង្រៀន | សាលាបឋមដំណាក់ត្រយឹង | បន្ទាយមាស |
| ១៨១ | លោកស្រី | អ៊ុក | សិរី | គ្រូបង្រៀន | សាលាបឋម សំព័រ | បន្ទាយមាស |
| ១៨២ | លោក | ស៊ូ | ចាន់ | គ្រូបង្រៀន | អនុ.គាថាវង្ស | បន្ទាយមាស |

| | | | | | | |
|---|---|---|---|---|---|---|
| ១៨៣ | លោក | ចាន់ | ជ្រៀប | គ្រូបង្រៀន | អនុ. ដើមពោធិ | បន្ទាយមាស |
| ១៨៤ | លោក | ភាំង | ស៊ីថា | គ្រូបង្រៀន | វិទ្យាល័យទូកមាស | បន្ទាយមាស |
| ១៨៥ | លោក | អ៊ុំ | សារឿន | គ្រូបង្រៀន | សាលាបឋម បន្ទាយមាស | បន្ទាយមាស |
| ១៨៦ | លោក | ចេវ | អ៊ាន | គ្រូបង្រៀន | សាលាបឋម កោះភាំង | បន្ទាយមាស |
| ១៨៧ | លោកស្រី | ទូច | ចាន់សុភា | គ្រូបង្រៀន | សាលាបឋម អង្គម្លី | បន្ទាយមាស |
| ១៨៨ | លោក | អ៊ុក | ស៊ីនី | គ្រូបង្រៀន | សាលាបឋម ព្រៃក្រឡា | បន្ទាយមាស |
| ១៨៩ | លោក | ឈៀវ | ច្រុង | គ្រូបង្រៀន | សាលាបឋម ពញាអង្គរ | បន្ទាយមាស |
| ១៩០ | លោក | សេង | សុវណ្ណមុនី | គ្រូបង្រៀន | វិទ្យាល័យព្រះរាជសម្ភារ | ក្រុង កំពត |
| ១៩១ | លោក | នាក់ | សុផល | គ្រូបង្រៀន | វិទ្យាល័យព្រះរាជសម្ភារ | ក្រុង កំពត |
| ១៩២ | លោកស្រី | កុល | សោភា | គ្រូបង្រៀន | អនុវិទ្យាល័យកំពតក្រុង | ក្រុង កំពត |
| ១៩៣ | លោកស្រី | ខែម | ភិន | គ្រូបង្រៀន | អនុវិទ្យាល័យកំពតក្រុង | ក្រុង កំពត |
| ១៩៤ | លោកស្រី | ងួន | ម៉ារីវិមល | គ្រូបង្រៀន | សាលាបឋម កំពតក្រុង | ក្រុង កំពត |
| ១៩៥ | លោកស្រី | ជា | ថៃ | គ្រូបង្រៀន | សាលាបឋម រស្មីសង្គ្រោះ | ក្រុង កំពត |
| ១៩៦ | លោកស្រី | ទឹម | ច័ន្ទបូរ | គ្រូបង្រៀន | សាលាបឋម ពិជ័យឧត្តុង្គ | ក្រុង កំពត |
| ១៩៧ | លោក | អ៊ុក | សាវី | គ្រូបង្រៀន | សាលាបឋម ១មករា | ក្រុង កំពត |
| ១៩៨ | លោក | ទូច | រក្សា | គ្រូបង្រៀន | សាលាបឋម បឹងតាព្រាម | ក្រុង កំពត |
| ១៩៩ | លោក | ចាប | ឆាំ | គ្រូបង្រៀន | វិទ្យាល័យព្រះរាជសម្ភារ | ក្រុង កំពត |
| ២០០ | លោក | ជ្រុន | សោភ័ណ្ឌ | គ្រូបង្រៀន | វិទ្យាល័យព្រះរាជសម្ភារ | ក្រុង កំពត |
| ២០១ | លោក | យឹម | នាវ | គ្រូបង្រៀន | វិទ្យាល័យព្រះរាជសម្ភារ | ក្រុង កំពត |
| ២០២ | លោកស្រី | ឡុង | សុមាលី | គ្រូបង្រៀន | អនុ.កំពតក្រុង | ក្រុង កំពត |
| ២០៣ | លោកស្រី | សុទ្ធ | សេដ្ឋារី | គ្រូបង្រៀន | អនុ.កំពតក្រុង | ក្រុង កំពត |
| ២០៤ | លោកស្រី | ឃុន | សំបូរ | គ្រូបង្រៀន | សាលាគរុកោសល្យ ខេត្ត | ក្រុង កំពត |
| ២០៥ | លោកស្រី | សូ | សុជាតា | គ្រូបង្រៀន | សាលាបឋម ប្រភ្នំ | អង្គរជ័យ |
| ២០៦ | លោក | ចាប | ផែម | គ្រូបង្រៀន | សាលាបឋម ម្រោម | អង្គរជ័យ |
| ២០៧ | លោក | ប៉ែន | ធន | គ្រូបង្រៀន | វិ. ជាស៊ីមអង្គរជ័យ | អង្គរជ័យ |
| ២០៨ | លោក | អ៊ឹម | សារិត | គ្រូបង្រៀន | វិ. ជាស៊ីមអង្គរជ័យ | អង្គរជ័យ |
| ២០៩ | លោក | ខៀវ | ស៊ីថាន | គ្រូបង្រៀន | អនុ.វត្តអង្គរជ័យ | អង្គរជ័យ |

| | | | | | | |
|---|---|---|---|---|---|---|
| ២១០ | លោកស្រី | ចិន | សារី | គ្រូបង្រៀន | អនុ.អង្គ ជោតិ | អង្គរជ័យ |
| ២១១ | លោកស្រី | ធៀន | មុំ | គ្រូបង្រៀន | អនុ.ត្រពាំងត្រកៀត | អង្គរជ័យ |
| ២១២ | លោកស្រី | កែ | ច័ន្ទណារី | គ្រូបង្រៀន | វិ.ហ ស អង្គស្លុក | អង្គរជ័យ |
| ២១៣ | លោកស្រី | ជិន | សុខា | គ្រូបង្រៀន | អនុ.ជោតិសុវណ្ណារ៉ាម | អង្គរជ័យ |
| ២១៤ | លោក | ម៉ក់ | សារ៉ិន | គ្រូបង្រៀន | សាលាបឋម ប្រភ្នំ | អង្គរជ័យ |
| ២១៥ | លោកស្រី | អ៊ូ | សុវត្ថិ | គ្រូបង្រៀន | សាលាបឋម យសមន្ត្រី | អង្គរជ័យ |
| ២១៦ | លោកស្រី | តូច | ស៊ីមេត | គ្រូបង្រៀន | សាលាបឋម អង្គពន្លឺ | អង្គរជ័យ |
| ២១៧ | លោកស្រី | ខៀវ | ម៉ាញ់ | គ្រូបង្រៀន | សាលាបឋមត្រពាំងត្រកៀត | អង្គរជ័យ |
| ២១៨ | លោកស្រី | អ៊ុក | ចំរុង | គ្រូបង្រៀន | សាលាបឋមត្រពាំងត្រកៀត | អង្គរជ័យ |
| ២១៩ | លោកស្រី | ទៀង | អ៊ុន | គ្រូបង្រៀន | សាលាបឋម ស្រែជា | អង្គរជ័យ |
| ២២០ | លោក | ខាន់ | ហាក់ | គ្រូបង្រៀន | សាលាបឋម សំឡាញ | អង្គរជ័យ |
| ២២១ | លោកស្រី | ស៊ឹម | ភិរម្យ | គ្រូបង្រៀន | សាលាបឋម អេងមាសតានី | អង្គរជ័យ |
| ២២២ | លោកស្រី | ណុប | សុភាង | គ្រូបង្រៀន | សាលាបឋម អេងមាសតានី | អង្គរជ័យ |
| ២២៣ | លោកស្រី | អ៊ិន | លី | គ្រូបង្រៀន | សាលាបឋម រលាំង | អង្គរជ័យ |
| ២២៤ | លោកស្រី | ជុំ | ចាន់មិត្ត | គ្រូបង្រៀន | សាលាបឋម អង្គខ្វាយ | អង្គរជ័យ |
| ២២៥ | លោកស្រី | ណុប | ម៉ាលី | គ្រូបង្រៀន | បឋមខៀវនៃអែមអង្គស្លុក | អង្គរជ័យ |
| ២២៦ | លោក | ហែម | សំអាង | គ្រូបង្រៀន | សាលាបឋម ព្រៃឃ្មែ | ជុំគិរី |
| ២២៧ | លោក | ម៉ម | រ៉ាន | គ្រូបង្រៀន | បឋមអង្គមន្ត្រីសត្ថារ៉ាម | ជុំគិរី |
| ២២៨ | លោកស្រី | អ៊ិន | ម៉ាឡែន | គ្រូបង្រៀន | សាលាបឋម តាភុល | ជុំគិរី |
| ២២៩ | លោក | ជុន | សោភ័ណ្ឌ | គ្រូបង្រៀន | សាលាបឋមស្រែសំរោង | ជុំគិរី |
| ២៣០ | លោក | សុខ | នា | គ្រូបង្រៀន | សាលាបឋម ពោធិវង្ស | ជុំគិរី |
| ២៣១ | លោក | លី | វុត | គ្រូបង្រៀន | សាលាបឋម អង្គអណ្តែត | ជុំគិរី |
| ២៣២ | លោក |ឃីន | ម៉ុល | គ្រូបង្រៀន | សាលាបឋម សាមគ្គី | ជុំគិរី |
| ២៣៣ | លោក | ធឿន | ចាន់ធឿន | គ្រូបង្រៀន | បឋមអម្ពវ័ន្តយោធារ៉ាម | ជុំគិរី |
| ២៣៤ | លោកស្រី | ហម | សារ៉ុម | គ្រូបង្រៀន | សាលាបឋមព្រៃឃ្មែ | ជុំគិរី |
| ២៣៥ | លោក | នង | វណ្ណៈ | គ្រូបង្រៀន | សាលាបឋម ត្រពាំងជ្រៃ | កំពង់ត្រាច |
| ២៣៦ | លោកស្រី | សេង | យោង | គ្រូបង្រៀន | សាលាបឋម ឧត្តមមានជ័យ | កំពង់ត្រាច |

| | | | | | | |
|---|---|---|---|---|---|---|
| ២៣៧ | លោកស្រី | នឹម | សារេត | គ្រូបង្រៀន | សាលាបឋម តន់ហាន់ | កំពង់ត្រាច |
| ២៣៨ | លោក | អ៊ិន | សារី | គ្រូបង្រៀន | សាលាបឋម ដើមស្វាយ | កំពង់ត្រាច |
| ២៣៩ | លោកស្រី | សៅ | គន្ធា | គ្រូបង្រៀន | សាលាបឋម ដំណាក់ក្រឡាញ់ | កំពង់ត្រាច |
| ២៤០ | លោក | កែវ | ជ្រុន | គ្រូបង្រៀន | សាលាបឋម ហ សបឹងធំ | កំពង់ត្រាច |
| ២៤១ | លោកស្រី | កុល | ស៊ីណា | គ្រូបង្រៀន | សាលាបឋម វត្តអូរ | កំពង់ត្រាច |
| ២៤២ | លោក | ឡេង | មុំ | គ្រូបង្រៀន | សាលាបឋម កោះផ្ដៅ | កំពង់ត្រាច |
| ២៤៣ | លោក | ជ័យ | ខុន | គ្រូបង្រៀន | សាលាបឋម ថ្មបើក | កំពង់ត្រាច |
| ២៤៤ | លោក | ចៅ | សារ៉ាន់ | គ្រូបង្រៀន | សាលាបឋម កោះទ្រមូង | កំពង់ត្រាច |
| ២៤៥ | លោក | ម៉ក់ | ប្រុស | គ្រូបង្រៀន | សាលាបឋម កំពូលមាស | កំពង់ត្រាច |
| ២៤៦ | លោក | អ៊ុង | ឆេត | គ្រូបង្រៀន | សាលាបឋម ឬស្សីស្រុក | កំពង់ត្រាច |
| ២៤៧ | លោកស្រី | ម៉ៅ | ធីតា | គ្រូបង្រៀន | សាលាបឋម ដំណាក់ត្របែក | កំពង់ត្រាច |
| ២៤៨ | លោកស្រី | ទន់ | សុគន្ធា | គ្រូបង្រៀន | សាលាបឋម អង្គគ្រឹះស្នា | កំពង់ត្រាច |
| ២៤៩ | លោក | ទូន | ស្រេង | គ្រូបង្រៀន | អនុ.កំពូលមាស | កំពង់ត្រាច |
| ២៥០ | លោក | លី | ប៊ុនឆាយ | គ្រូបង្រៀន | អនុ.ឧត្ដមមានជ័យ | កំពង់ត្រាច |
| ២៥១ | លោក | សែស | ផាន | គ្រូបង្រៀន | វិ.ព្រះបិតាថវិកាជាតិ | កំពង់ត្រាច |
| ២៥២ | លោក | ង៉ែត | បូរុន | គ្រូបង្រៀន | វិ.ព្រះបិតាថវិកាជាតិ | កំពង់ត្រាច |
| ២៥៣ | លោក | នួន | សេង | គ្រូបង្រៀន | វិទ្យាល័យ អង្គសុរភី | កំពង់ត្រាច |
| ២៥៤ | លោក | អ៊ឹង | ឈុំវុឌ្ឍី | គ្រូបង្រៀន | វិទ្យាល័យ អង្គសុរភី | កំពង់ត្រាច |
| ២៥៥ | លោក | មៀច | ម៉ន | គ្រូបង្រៀន | អនុ.ឧត្ដមមានជ័យ | កំពង់ត្រាច |
| ២៥៦ | លោក | ឃុយ | សៀនភេនីរៈ | គ្រូបង្រៀន | អនុ.ដើមស្វាយ | កំពង់ត្រាច |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូ
អនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៥ . អនក្រ . បក

# អនុក្រឹត្យ

# ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ត្រីអង្គការក្រៅរដ្ឋាភិបាល ចំនួន ០៩រូប ដែលមានគុណបំណាច់ និង ស្នាដៃល្អ ក្នុងការបម្រើជាតិមាតុភូមិនាពេលកន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ:**

១- លោក **ហ៊ូ ឧត្តរី** អគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ

២- លោក **អ៊ុក សមវិទ្យា** នាយកបេឡាជាតិរបបសន្តិសុខសង្គម

៣- លោក **ម៉ែន សុចិត្រ** នាយកខុទ្ទកាល័យ

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា:**

១- លោក **ជូរ អឿនលី** អនុប្រធាននាយកដ្ឋានមុខរបរនិងហត្ថពលកម្ម

២- លោក **អៀម គន្ធឌី** អនុប្រធាននាយកដ្ឋានស្តង់ដាជាតិសមត្ថភាព

**គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ:**

១- លោក **ហែម ប៊ុនធី** ប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូន សាលាមិត្តភាព T80 នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងគណៈគ្រប់គ្រង ចំនួន០៥រូប ដែលបានជួយបណ្តុះបណ្តាលភាសាវៀតណាម ដល់និស្សិតកម្ពុជា តាំងពីឆ្នាំ ១៩៨៥ រហូតដល់បច្ចុប្បន្ន ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ :**

-**សាលាមិត្តភាព T 80**

**ខ-មេដាយសហមេត្រី ថ្នាក់ សេនា :**

| | | |
|---|---|---|
| ១-លោកស្រី | **Vu Thi Anh** | នាយិកា សាលា |
| ២-លោក | **Troung Manh Hung** | នាយករង សាលា |

**គ-មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ :**

| | | |
|---|---|---|
| ១-លោក | **Chu Van Viet** | ប្រធានការិយាល័យ សាលា |
| ២-លោក | **Do Trong Suong** | អនុប្រធានការិយាល័យ សាលា |
| ៣-លោក | **Nguyen Vinh Tru** | អនុប្រធានការិយាល័យ សាលា |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១០*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

| | | | |
|---|---|---|---|
| ២- | លោក | គង់ ចំន្ទតារា | នាយខុទ្ទកាល័យ |
| ៣- | លោក | ថូ ម៉ុនថន | អនុប្រធាននាយកដ្ឋានអធិការកិច្ច |
| ៤- | លោក | ជា កុសល | ប្រធានគំរោងអង្គការ Winrock |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...០៤...សសរ.

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការដឹកនាំការងារ ដើម្បីពិនិត្យ ដោះស្រាយបញ្ហាប្រាក់ឧបត្ថម្ភបន្ថែម ក្នុងក្របខ័ណ្ឌគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- តាមស្មារតីអង្គប្រជុំអន្តរក្រសួង ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ ស្តីពីការជំរុញការអនុវត្តអនុក្រឹត្យលេខ ២០៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបញ្ចប់ការអនុវត្តកម្មវិធីកម្មវិធីកន្សោមអាទិភាព និងប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ
- តាមការចាំបាច់

## សម្រេច

**ប្រការ១ :** បង្កើតគណៈកម្មាធិការដឹកនាំការងារ ដើម្បីពិនិត្យ ដោះស្រាយបញ្ហាប្រាក់ឧបត្ថម្ភបន្ថែម ក្នុងក្របខ័ណ្ឌគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ ដែលមានសមាសភាពដូចតទៅ :

| | | | | | |
|---|---|---|---|---|---|
| ១. | ឯកឧត្តម | **សុខ** | **អាន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | ប្រធាន |
| ២. | ឯកឧត្តម | **គាត** | **ឈន់** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. | ឯកឧត្តម | **អ៊ឹម** | **ឈុនលឹម** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៤. | ឯកឧត្តម | **ឆាយ** | **ថន** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ | សមាជិក |
| ៥. | ឯកឧត្តម | **ចម** | **ប្រសិទ្ធ** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦. | ឯកឧត្តម | **លឹម** | **គានហោ** | រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៧. | ឯកឧត្តម | **ខៀវ** | **កាញារីទ្ធ** | រដ្ឋមន្ត្រីក្រសួងព័ត៌មាន | សមាជិក |
| ៨. | ឯកឧត្តម | **ចាន់** | **សារុន** | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩. | លោកជំទាវ | **អ៊ឹង** | **កន្ថាផាវី** | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | សមាជិក |
| ១០. | លោកជំទាវ | **សោម** | **គីមសួគ៍** | រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ១១. | ឯកឧត្តម | **ម៉ម** | **ប៊ុនហេង** | រដ្ឋមន្ត្រីក្រសួងសុខាភិបាល | សមាជិក |
| ១២. | ឯកឧត្តម | **អ៊ឹម** | **សេិទ្ធី** | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៣. | ឯកឧត្តម | **ត្រាំ** | **អ៊ីវតឹក** | រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៤. | ឯកឧត្តម | **ជា** | **សុផារ៉ា** | រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៥. | ឯកឧត្តម | **ច្រាក់** | **សុខុន** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអនុប្រធានអាជ្ញាធរមីនកម្ពុជា | សមាជិក |
| ១៦. | ឯកឧត្តម | **អូន** | **ព័ន្ធមុនីរ័ត្ន** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| ១៧. | ឯកឧត្តម | **ទ្រាំ** | **សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១៨. | ឯកឧត្តម | **ឈៀង** | **យ៉ាណរ៉ា** | អគ្គលេខាធិការ-គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៩. | ឯកឧត្តម | **ពេជ្រ** | **ប៊ុនធិន** | រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| ២០. | ឯកឧត្តម | **ង៉ោ** | **ហុងលី** | អគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | សមាជិកអចិន្ត្រៃយ៍ |

**ប្រការ២** : គណៈកម្មាធិការដឹកនាំការងារនេះ មានតួនាទី និងភារកិច្ចសំខាន់ៗ ដូចខាងក្រោម :

- ពិនិត្យលើរបាយការណ៍នៃការសិក្សា វាយតម្លៃ និងការស្នើសុំយោបល់ដោះស្រាយរបស់ក្រុមការងារបច្ចេកទេស លើគម្រោង និងកម្មវិធីដែលទទួលបានប្រាក់ឧបត្ថម្ភបន្ថែមដោយដៃគូអភិវឌ្ឍដែលបាន និងកំពុងអនុវត្តនៅតាមបណ្តាក្រសួង ស្ថាប័នរដ្ឋ និងចំណុចពាក់ព័ន្ធទៅនឹងប្រព័ន្ធបៀវត្សរបស់រដ្ឋ
- ពិនិត្យ និងអនុម័តលើទម្រង់បែបបទដែលជាស្តង់ដានៃការចំណាយប្រតិបត្តិការប្រចាំថ្ងៃ ក្នុងក្របខ័ណ្ឌគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ
- គោរពរាយការណ៍ជូនសម្តេចនាយករដ្ឋមន្ត្រី ដើម្បីសុំការសម្រេចចុងក្រោយលើដំណោះស្រាយនៃបញ្ហាប្រាក់ឧបត្ថម្ភបន្ថែម ក្នុងក្របខ័ណ្ឌគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការចង្អុលទិសរបស់រាជរដ្ឋាភិបាល ។

**ប្រការ៣** : អនុប្រធាន និងសមាជិកទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ គណៈកម្មាធិការដឹកនាំការងារ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីអនុវត្តការងារ ។

**ប្រការ៤** : គណៈកម្មាធិការដឹកនាំការងារ ដើម្បីពិនិត្យ ដោះស្រាយបញ្ហាប្រាក់ឧបត្ថម្ភបន្ថែម ក្នុងក្របខ័ណ្ឌគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ ត្រូវមានក្រុមការងារបច្ចេកទេសមួយជាសេនាធិការ សម្រាប់បំពេញការងារប្រចាំថ្ងៃ និងអនុវត្តការងារតាមការចង្អុលទិសរបស់គណៈកម្មាធិការ ដែលមានសមាសភាពដូចខាងក្រោម :

| | | | | | |
|---|---|---|---|---|---|
| ១. | ឯកឧត្តម | **ង៉ោ** | **ហុងលី** | អគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | ប្រធាន |
| ២. | ឯកឧត្តម | **វង្សី** | **វិស្សុត** | អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. | ឯកឧត្តម | **សក់** | **សេដ្ឋា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៤. | ឯកឧត្តម | **អេង** | **ហួត** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៥. | ឯកឧត្តម | **រឹុត** | **វុទ្ធី** | អគ្គលេខាធិការរង-គណៈកម្មាធិការទីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៦. | ឯកឧត្តម | **ប៉ុល** | **ពីឌុ** | អគ្គលេខាធិការរងនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | សមាជិកអចិន្ត្រៃយ៍ |
| ៧. | ឯកឧត្តម | **ឆាយ** | **ឆត្រាវុធ** | អគ្គលេខាធិការរងនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | សមាជិក |
| ៨. | ឯកឧត្តម | **ចាន់** | **សុធី** | ប្រធាននាយកដ្ឋានវិនិយោគសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩. | លោក | **យស់** | **ម៉ុនណារា** | ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ៥** : ក្រុមការងារបច្ចេកទេស មានតួនាទី និងភារកិច្ចមួយចំនួនដូចខាងក្រោម :

- ពិនិត្យ និងកំណត់និយមន័យ រួមទាំងទម្រង់នានានៃការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមដែលបាន និងកំពុងអនុវត្តនៅតាមគម្រោង និងកម្មវិធីគាំទ្រដោយដៃគូអភិវឌ្ឍ នៅតាមបណ្តាក្រសួង និងស្ថាប័ននានារបស់រដ្ឋ
- ពិនិត្យឡើងវិញនូវគម្រោង និងកម្មវិធីដែលបានទទួលប្រាក់ឧបត្ថម្ភបន្ថែមដោយដៃគូអភិវឌ្ឍដែលបាន និងកំពុងអនុវត្តនៅតាមបណ្តាក្រសួង និងស្ថាប័ននានារបស់រដ្ឋ
- សិក្សា និងរៀបចំបែបបទ ដើម្បីកំណត់ស្តង់ដាសម្រាប់ការផ្ទេរពី " ការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមដែលគាំទ្រដោយដៃគូអភិវឌ្ឍ មកជា " ការចំណាយប្រតិបត្តិការប្រចាំថ្ងៃ "
- រៀបចំរបាយការណ៍ ស្តីពីលទ្ធផលនៃការសិក្សា វាយតម្លៃ និងដំណោះស្រាយលើបញ្ហាប្រាក់ឧបត្ថម្ភបន្ថែមជូនគណៈកម្មាធិការដឹកនាំការងារ ដើម្បីពិនិត្យ និងសម្រេច
- បំពេញការងារផ្សេងៗទៀត តាមការណែនាំរបស់គណៈកម្មាធិការដឹកនាំការងារ
- មានសិទ្ធិអញ្ជើញប្រធានគម្រោង ឬកម្មវិធីគាំទ្រដោយដៃគូអភិវឌ្ឍ មន្ត្រីជំនាញបច្ចេកទេសមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍពាក់ព័ន្ធដោយផ្ទាល់ តាមការចាំបាច់ ដើម្បីប្រជុំ ពិភាក្សា និងពិគ្រោះយោបល់ ។

**ប្រការ៦** : ក្រុមការងារបច្ចេកទេស មានទីតាំងអនុវត្តការងារ នៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងមានសិទ្ធិប្រើប្រាស់មន្ត្រីរាជការរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល សម្រាប់បំពេញការងារ បន្ថែមលើសមាសភាពដែលបានកំណត់ក្នុងសេចក្តីសម្រេចនេះ ។

**ប្រការ៧** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ និងប្រការ៤ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ
- រាជកិច្ច

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**Kingdom of Cambodia**
Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry, Mines and Energy**
លេខ : ០.៩៤៨ ឧ.ប.ក.ពង.ព្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញលិខិតលេខ ២៥៨៣/០៩ គ.វ.ក ចុះថ្ងៃទី០១.១២.២០០៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន យីង ដុង ស៊ូ ខូ អិលធីឌី ចុះថ្ងៃទី១៨.១១.២០០៩

## សំរេច

**ប្រការ១ :**

-អនុញ្ញាតឱ្យក្រុមហ៊ុន យីង ដុង ស៊ូ ខូ អិលធីឌី តំណាងដោយ លោក ឈីវ ជីងធីង សញ្ជាតិខ្មែរ អាយុ៥២ឆ្នាំ កាន់អត្តសញ្ញាណបណ្ណ័លេខ 130096666 ចុះថ្ងៃទី០៨.១០.២០០៨ មានអាសយដ្ឋានបច្ចុប្បន្ន : ក្រុម១៤ ភូមិ១ សង្កាត់លេខ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម : ពិ៥ជ

ឈ្មោះផលិតផល

លេខចុះបញ្ជីផលិតផល ISIC Code

**ស្បែកជើង**

៣២៤០

-ផ្លាកឈ្មោះ រោងចក្រ : " **យីង ដុង ស៊ូ ខូ អិលធីឌី ( YING DONG SHOES CO., LTD.)** "

-ទីតាំងរោងចក្រ : " *ភូមិកន្ទោកជើង ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល* "

**ប្រការ២ :**

-ម្ចាស់រោងចក្រត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឱ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណាផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណី ដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣ :**

-ម្ចាស់រោងចក្រ ត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យ ដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសំរេចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម លេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានាស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤ :**

ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬប្រគល់សិទ្ធិឱ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប៉ុន្តែក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និង គុណភាពផលិតផល របស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥ :**

ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាស ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬ ចាត់ឱ្យមករៀបចំរោងចក្របានឡើយ ។

**ប្រការ៦ :**

ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីខាងមុខរោងចក្រ ។

**ប្រការ៧:**

-មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឱ្យម្ចាស់រោងចក្រ មានសុពលភាព ០៣ឆ្នាំ តាមលក្ខខណ្ឌដូចខាងក្រោម :

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និង ផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូ ដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ជិកាកម្មរោងចក្រប្រចាំ ០៣ឆ្នាំ។

**ប្រការ៨ :**

-ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាពនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩ :**

-ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឱ្យអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយនៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុងអំឡុងពេលសប្តាហ៍ទីមួយនៃខែមករានៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រនឹងត្រូវទទួលទោសប្បញ្ញត្តិតាមមាត្រា ៤៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:**

រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និង ការចុះបញ្ជីផលិតផល ។

**ប្រការ១១:**

លក្ខខណ្ឌនានា របស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ ។

**ប្រការ១២:**

ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល ១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:**

-ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចស្របតាមមាត្រា ៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹងមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

-ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រយៈពេល១ខែ យ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រ ជាស្ថាពរ ។

**ប្រការ១៤:**

ប្រកាសលេខ ៦៣៨ ផក.ប្រក ចុះថ្ងៃទី២៤.០៦.១៩៩៧ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ដាយ៉ូ ខេមបូឌា អិលធីឌី ដែលមានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ ភូមិអង្គកែវ ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៥:**

អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀង១ខ្លួន ។

**ប្រការ១៦:**

ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រាជកិច្ច

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-សាលាខេត្តកណ្តាល

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៥ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

**គណៈកម្មការសុរិយោដីថ្នាក់ជាតិ**

លេខ : ០៣៧ ប្រក.ដនស/គសជ

# ប្រកាស

## ស្តីពី

## ការធ្វើប្រតិភូកម្មមុខងារជូនអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈកម្មការសុរិយោដី រាជធានី ខេត្ត ដើម្បីធ្វើសេចក្តីសម្រេចលើសំណុំរឿងវិវាទដីធ្លីក្នុងយន្តការរបស់គណៈកម្មការសុរិយោដី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១០៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៤៧អនក្របក. ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- បានឃើញអនុក្រឹត្យលេខ ៣៤អនក្រ.បក. ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦ ស្តីពីការកែប្រែមាត្រា ៥ និងមាត្រា ២៨ នៃអនុក្រឹត្យលេខ ៤៧អនក្របក. ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

- បានឃើញប្រកាសលេខ ១១២ដនស.ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី
- បានឃើញប្រកាសអន្តរក្រសួងលេខ ០២ប្រក.០៣. ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី
- បានឃើញសេចក្តីណែនាំរួមលេខ ០៥សណន. ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៦ ស្តីពីការអនុវត្តន៍អនុក្រឹត្យលេខ ៣៤អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦
- យោងសេចក្តីជូនដំណឹងលេខ ១៦៧៤ សជណ.ខុស. ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**ប្រការ១ :** ត្រូវបានធ្វើប្រតិភូកម្មមុខងារជូនអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈកម្មការសុរិយោដីរាជធានី ខេត្ត ដើម្បីធ្វើសេចក្តីសម្រេចលើករណីវិវាទដីធ្លីក្នុងយន្តការរបស់គណៈកម្មការសុរិយោដី ។

**ប្រការ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៣ :** នាយកខុទ្ទកាល័យ ប្រធានលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ គណៈកម្មការសុរិយោដីរាជធានី ខេត្ត ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ប្រធានលេខាធិការដ្ឋានគណៈកម្មការសុរិយោដីរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ២០១០

ទេសរដ្ឋមន្ត្រី

អ៊ឹម ឈុនលឹម

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- សមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ
- សមាជិកគណៈកម្មការសុរិយោដីរាជធានី ខេត្ត
- ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពជុំវិញក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ដូចប្រការ ៣
- រាជកិច្ច
- ក្រុមការងារគេហទំព័រក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការសុរិយោដីរាជធានី-ខេត្ត ....................

លេខ : ......................

## សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីរាជធានី-ខេត្ត..........

-បានឃើញរាជក្រមលេខ នស.រកម ០៨០១.១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលបានប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ. ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មការសុរិយោដី

-បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក.ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ២០០៦ ស្តីពីការកែប្រែមាត្រា ៥ និងមាត្រា ២៨ នៃអនុក្រឹត្យលេខ ៤៧ អនក្របក.ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

-បានឃើញប្រកាសលេខ ១១២ ដនស/ប្រក ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០២ ស្តីពី គោលការណ៍ណែនាំ និង នីតិវិធីរបស់គណៈកម្មការសុរិយោដី

-បានឃើញប្រកាសលេខ.........ដនស/គសជចុះថ្ងៃទី........ខែ........ឆ្នាំ២០១០ស្តីពីការធ្វើប្រតិភូកម្មជូនអភិបាលនៃគណៈអភិបាល និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្តដើម្បីធ្វើសេចក្តីសម្រេចលើករណីវិវាទដីធ្លីក្នុងយន្តការរបស់គណៈកម្មការសុរិយោដី

-បានឃើញសារាចរណែនាំលេខ.............ដនស/គសជ ចុះថ្ងៃទី.......ខែ..........ឆ្នាំ ស្តីពី របៀបរបបនៃការធ្វើសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្តលើសំណុំរឿងវិវាទដីធ្លីក្នុងយន្តការគណៈកម្មការសុរិយោដី

-យោងតាមសំណុំរឿងវិវាទដែលបានបញ្ជូនមកពីគណៈកម្មការសុរិយោដីថ្នាក់ក្រុង-ស្រុក-ខណ្ឌ....................ដែលមិនអាចសម្រុះសម្រួលបញ្ចប់វិវាទដោយជោគជ័យជាលើកចុងក្រោយកាលពីថ្ងៃទី..........ខែ............ឆ្នាំ .................. នៅគណៈកម្មការសុរិយោដីរាជធានី-ខេត្ត.......................

-យោងកិច្ចប្រជុំនៅថ្ងៃទី........ខែ.........ឆ្នាំ............របស់គណៈកម្មការសុរិយោដីរាជធានី ខេត្ត........................ ដើម្បីពិនិត្យសម្រេចលើ សំណុំរឿង វិវាទលេខ............................ចុះថ្ងៃទី..........ខែ...........ឆ្នាំ ដូចខាងក្រោមនេះ :

១. **ការពិនិត្យអង្គហេតុ:**

**ក. អំពីភាគីវិវាទ :**

ឈ្មោះរបស់ដើមបណ្តឹង________________ ថ្ងៃខែឆ្នាំកំណើត__________

ភេទ______ សញ្ជាតិ__________ មុខរបរ____________

អាសយដ្ឋានរបស់ដើមបណ្តឹង:________________________

______________________________________________

______________________________________________

______________________________________________

ឈ្មោះរបស់ចុងបណ្តឹង________________ ថ្ងៃខែឆ្នាំកំណើត__________

ភេទ______ សញ្ជាតិ__________ មុខរបរ____________

អាសយដ្ឋានរបស់ចុងបណ្តឹង:________________________

______________________________________________

______________________________________________

______________________________________________

**ខ. អំពីជីវិវាទ:** (ភ្ជាប់ទំព័របន្ថែមបើចាំបាច់)

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

**គ. សេចក្តីសង្ខេបអំពីវិវាទ:**(ភ្ជាប់ទំព័របន្ថែមបើចាំបាច់)

______________________________________________

______________________________________________

______________________________________________

**ឃ. សេចក្តីសង្ខេបអំពីដំណើរការដោះស្រាយវិវាទ :**(ភ្ជាប់ទំព័របន្ថែមបើចាំបាច់)

**ង. សេចក្តីសន្និដ្ឋានទៅលើអង្គហេតុ:** (ភ្ជាប់ទំព័របន្ថែមបើចាំបាច់)

(1)

(2)

(3)

(4)

(5)

**ច. សេចក្តីសន្និដ្ឋានទៅលើអង្គច្បាប់ :** (ភ្ជាប់ទំព័របន្ថែមបើចាំបាច់)

(1)

(2)

(3) ______________________________________________

______________________________________________

(4) ______________________________________________

______________________________________________

(5) ______________________________________________

______________________________________________

**៣. សេចក្តីសំរេចៈ** (ភ្ជាប់ទំព័របន្ថែមបើចាំបាច់)

(1) ______________________________________________

______________________________________________

(2) ______________________________________________

______________________________________________

(3) ______________________________________________

______________________________________________

(4) ______________________________________________

______________________________________________

(5) ______________________________________________

______________________________________________

សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីរាជធានី-ខេត្ត........................នឹងចូលជាស្ថាពរ លើកលែងតែភាគីស្នើរសុំឱ្យគណៈកម្មការសុរិយោដីថ្នាក់ជាតិបើកសាវនាការឡើងវិញក្នុងកំឡុងពេល ៣០ថ្ងៃ បន្ទាប់ពីភាគីទទួលបានសេចក្តីសម្រេចពីគណៈកម្មការសុរិយោដី ឬថ្ងៃដែលបានជូនដំណឹងអំពីសេចក្តីសម្រេចនេះ។

..............: ថ្ងៃទី.......ខែ.............ឆ្នាំ..........

**ប្រធានគណៈកម្មការសុរិយោដីរាជធានី-ខេត្ត.............**

ឧបសម្ព័ន្ធ ខ ២៤ក

| គណៈកម្មការសុរិយោដី | | ខេត្ត | | ស្រុក | | ឆ្នាំ | | លេខ | | |
|---|---|---|---|---|---|---|---|---|---|---|
| លេខសំណុំរឿង | គ.ស.ស.ខ | | | | | | | | | |
| លេខសំណុំរឿង | គ.ស.ខ.ក | [redacted] | | | | | | | | |
| លេខសំណុំរឿង | គ.ស.ជ | | | | | | | | | |

# ទម្រង់បែបបទស្នើសុំបើកសវនាការឡើងវិញ

| ព័ត៌មានអំពីអ្នកស្នើសុំសវនាការឡើងវិញ (អតីតដើមបណ្តឹង☐ ឬចុងបណ្តឹង☐) | | | | | |
|---|---|---|---|---|---|
| ឈ្មោះអ្នកស្នើសុំ : | | ថ្ងៃខែឆ្នាំកំណើត: | ប្រុស ☐ ស្រី ☐ | សញ្ជាតិ: | មុខរបរ: |
| ឈ្មោះប្តី ឬ ប្រពន្ធ: | | | ចំនួនកូន: | | |
| **ទីលំនៅបច្ចុប្បន្នរបស់អ្នកស្នើសុំ** | | | | | |
| រាជធានី ខេត្ត : | ក្រុង ស្រុក ខណ្ឌ: | ឃុំ សង្កាត់: | ភូមិ: | ផ្លូវលេខ: | ផ្ទះលេខ: |
| **ទីតាំង និងទំហំដីដែលមានវិវាទ** | | | | | |
| រាជធានី ខេត្ត : | ក្រុង ស្រុក ខណ្ឌ: | ឃុំ សង្កាត់: | ភូមិ: | ផ្លូវលេខ: | ផ្ទះលេខ: |
| **ទំហំដីវិវាទ :** | | | | | |

| ព័ត៌មានអំពីភាគីម្ខាងទៀត (អតីតដើមបណ្តឹង☐ ឬចុងបណ្តឹង☐) (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើចាំបាច់) | |
|---|---|
| ឈ្មោះ : | ទីលំនៅបច្ចុប្បន្ន/ លេខទូរស័ព្ទ/: |
| ១. | |
| ២ | |

| សេចក្តីអធិប្បាយទទួនៅរបស់អ្នកស្នើសុំបើកសវនាការឡើងវិញ (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើចាំបាច់) | |
|---|---|
| យោងសេចក្តីសម្រេចលេខ | |
| ១.មិនសុខចិត្តលើសេចក្តីសម្រេចទាំងមូល | ☐ |
| ២.មិនសុខចិត្តលើសេចក្តីសម្រេចត្រង់ចំណុច | ទី១☐-ទី២☐-ទី៣☐-ទី៤☐-ទី៥☐ |
| ៣.ផ្សេងៗ | |
| | |
| | |

ទម្រង់ ទី ២៤ខ

| ឯកសារអំណះអំណាងថ្មីបន្ថែមប្រសិនជាមាន<br>( សូមភ្ជាប់ទំព័របន្ថែមប្រសិនបើចាំបាច់ ) | |
|---|---|
| ១. | ៤. |
| ២. | ៥. |
| ៣. | ៦. |

| សំណូមពរដោះស្រាយ ឬវិធានដោះស្រាយរបស់អ្នកស្នើសុំបើកសវនាការឡើងវិញ<br>( សូមភ្ជាប់ទំព័របន្ថែមប្រសិនបើចាំបាច់ ) |
|---|
| ១. |
| ២. |
| ៣. |
| ៤. |
| ៥. |

កាលបរិច្ឆេទ:................/.................../..................

ស្នាមមេដៃរបស់អ្នកស្នើសុំបើកសវនាការឡើងវិញ

កាលបរិច្ឆេទ: ______/______/______

ហត្ថលេខារបស់មន្ត្រីទទួលពាក្យបណ្តឹង

បានឃើញ

កាលបរិច្ឆេទ : .........../................./..........

ប្រធានគណៈកម្មការសុរិយោដី

**កំណត់សំគាល់ :**

-អ្នកស្នើសុំបើកសវនាការឡើងវិញអាចប្រើប្រាស់ទម្រង់បែបបទផ្សេងៗទៀតបាន ប៉ុន្តែត្រូវដាក់បញ្ចូលពត៌មានខាងលើនេះ

-អ្នកស្នើសុំបើកសវនាការឡើងវិញត្រូវផ្តិតមេដៃ និងចុះកាលបរិច្ឆេទនៅថ្ងៃដែលខ្លួនបានដាក់ពាក្យបណ្តឹងនៅចំពោះមុខមន្ត្រីទទួលពាក្យ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**
គណៈកម្មការសុរិយោដីថ្នាក់ជាតិ
លេខ : ០១ ដនស/សរណេទ

# សារាចរណែនាំ
# ស្តីពី
# ការអនុវត្តនីតិវិធីនៃការធ្វើសេចក្តីសម្រេចលើសំណុំរឿងវិវាទដីធ្លី របស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ក្នុងយន្តការគណៈកម្មការសុរិយោដី

អនុលោមតាមលិខិតលេខ ១៦៧៤សជណ.ឱស ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងប្រកាសលេខ ០៣២ប្រក.ដនស/គសជ. ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការធ្វើប្រតិភូកម្មមុខងារជូនដល់អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈកម្មការសុរិយោដីរាជធានី ខេត្ត ដើម្បីធ្វើសេចក្តីសម្រេចលើសំណុំរឿងវិវាទដីធ្លីក្នុងយន្តការរបស់គណៈកម្មការសុរិយោដី។ គណៈកម្មការសុរិយោដីថ្នាក់ជាតិសូមធ្វើការណែនាំអំពីការអនុវត្តនីតិវិធីនៃការធ្វើសេចក្តីសម្រេចដូចតទៅ :

